**សេចក្តីថ្លែងការណ៍**

**មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលបង្ហាញពីរបកគំហើញសំខាន់ៗពីការសង្កេតសវនាការរបស់ខ្លួននៅសាលាឧទ្ធរណ៍ទាំងបួន នៅឆ្នាំ២០២២**

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

ថ្ងៃនេះ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពី *"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា៖ ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ"* ដែលធ្វើឡើងចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។ របាយការណ៍នេះវិភាគលើទិន្នន័យ ដែលប្រមូលបានតាមរយៈការសង្កេតសវនាការប្រចាំថ្ងៃលើសំណុំរឿងព្រហ្មទណ្ឌចំនួន ៥២១ ដោយមិនបានកំណត់ជាក់លាក់លើសំណុំរឿងណាមួយ ដែលពាក់ព័ន្ធនឹងជនជាប់ចោទចំនួន ៧២៤ នាក់ នៅសាលាឧទ្ធរណ៍ទាំងបួនខាងលើ ដោយបានប្រើប្រាស់តារាងសង្កេតការណ៍សវនាការ ដែលបានរៀបចំយ៉ាងច្បាស់លាស់ក្នុងគោលបំណងវាយតម្លៃលើការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលបានកំណត់នៅក្នុងច្បាប់ជាតិ និងអន្តរជាតិ។

របាយការណ៍នេះរកឃើញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួនត្រូវបានធានានៅចំពោះមុខសាលាឧទ្ធរណ៍ទាំងបួនដូចជា សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។ ស្រដៀងគ្នានេះ សាលាឧទ្ធរណ៍បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ បានលើកកម្ពស់សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល នៅអំឡុងពេលធ្វើរបាយការណ៍នេះ។ សិទ្ធិផ្សេងៗទៀតក៏ត្រូវបានលើកកម្ពស់ផងដែរដោយសាលាឧទ្ធរណ៍ខ្លះ រួមមានសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់។

ទោះជាយ៉ាងណាក៏ដោយ របាយការណ៍នេះបានរកឃើញពីកង្វះការអនុលោមតាមបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួនដែលជាសិទ្ធិមូលដ្ឋានដោយសាលាឧទ្ធរណ៍ទាំងបួន ដូចជា សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព និងផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង សិទ្ធិមានសេរីភាព និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស។ ជាពិសេសទៀតនោះ ជនជាប់ចោទបន្តស្ថិតនៅក្នុងឃុំ រួមទាំងសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ និងជនជាប់ចោទចំនួនមួយភាគបីមិនមានមេធាវីការពារនៅពេលសវនាការ។ ទោះបីជា

យ៉ាងនេះក៏ដោយ ចៅក្រមបានគោរពពេញលេញតាមច្បាប់ជាតិ ដែលតម្រូវឱ្យមានមេធាវីការពារចំពោះបទឧក្រិដ្ឋ ឬសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ ប៉ុន្តែចំនួនមួយភាគបីនៃជនជាប់ចោទដែលមិនមានមេធាវីការពារនោះនៅតែមិនស្របតាមបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌នៅឡើយ។ របាយការណ៍នេះក៏ប្រៀបធៀបទិន្នន័យដែលប្រមូលបាននៅឆ្នាំ២០២២ ជាមួយនឹងរបាយការណ៍ឆ្នាំមុនៗនៅសាលាឧទ្ធរណ៍ភ្នំពេញ ដើម្បីកំណត់និន្នាការ និងវិភាគអំពីការវិវឌ្ឍនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

ម.ស.ម.ក សង្ឃឹមថា ទិន្នន័យ ការវិភាគ និងអនុសាសន៍ ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះនឹងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌ និងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ព្រមទាំងគាំទ្រដល់អ្នកដែលធ្វើការដើម្បីធានាថាប្រព័ន្ធយុត្តិធម៌នៅកម្ពុជាមានភាពត្រឹមត្រូវ និងស្មើភាពសម្រាប់ទាំងអស់គ្នា។ របាយការណ៍នេះអាចរកបាននៅលើគេហទំព័ររបស់ ម.ស.ម.ក ជាភាសាខ្មែរ និងភាសាអង់គ្លេស និងទិន្នន័យអាចរកបាននៅលើប្រព័ន្ធផ្ទុកទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក ហ៊ុន ស៊ាងហាក់ អ្នកសម្របសម្រួលគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក តាមរយៈអ៊ីមែល seanghak.hun@cchrcambodia.org ឬលេខទូរស័ព្ទ +៨៥៥ (0) ១២ ៤០ ៣០ ៥០។

– **ចប់** –

**បណ្ណាធិការ៖**

## អំពីគម្រោងសង្កេតការណ៍សវនាការ

គម្រោងសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានចាប់តាំងពីឆ្នាំ២០០៩ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌក្នុងតុលាការកម្ពុជា និងវាយតម្លៃអំពីការអនុវត្តបទដ្ឋានជាតិ និងអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌។ គម្រោងបានប្រើប្រាស់នូវរបកគំហើញដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងនៃគោលគំនិតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន។ គោលបំណងរួមរបស់គម្រោងគឺ ធ្វើឱ្យមានភាពប្រសើរឡើងផ្នែកនីតិវិធី និងការអនុវត្តរបស់តុលាការកម្ពុជាដែលធានាថាមានការគោរពយ៉ាងពេញលេញនូវបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ក្នុងសវនាការព្រហ្មទណ្ឌ ព្រមទាំងបង្កើនការយល់ដឹង និងចំណេះដឹងនៃគោលគំនិតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ ព្រមទាំងទិន្នន័យសង្កេការណ៍សវនាការ។ ឯកសារផ្សេងៗទៀតពាក់ព័ន្ធនឹងគម្រោងអាចរកបាននៅទីនេះ។

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ត្រូវបានបង្កើតនៅខែវិច្ឆិកា ឆ្នាំ២០០២ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅទូទាំងកម្ពុជា។ ម.ស.ម.ក គឺជាសមាជិកនៃដៃគូសន្ធនាអន្តជាតិដើម្បីសេរីភាពសម្តែងមតិ (IFEX) ជាបណ្តាញសកលលោកដើម្បីសេរីភាពសម្តែងមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រប់ការរួមរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិកនៃបណ្តាញប្រឆាំងនឹងទារុណកម្ម អែស អូ អែស និងជាសមាជិក OECD-Watch។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org បានទទួលពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងទទួលពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្វីនឡែនក្នុងទីក្រុងប្រីសប៊ែន (Brisbane) នៃប្រទេសអូស្ត្រាលី។